# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦៥២ សណន កសក

## សេចក្តីណែនាំ
## ស្តីពី
## វិធានការទប់ស្កាត់ការបាត់បង់បរិមាណនិងគុណភាពស្រូវរដូវវស្សាឆ្នាំ២០១៤ នៅក្នុងនិងក្រោយពេលប្រមូលផល

ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤នេះ តាមការចុះពិនិត្យ និងវាយតម្លៃជាក់ស្តែងឃើញថា សម្រេចបានលទ្ធផលគួរជាទីមោទនៈ បើទោះបីជានៅតាមតំបន់ខ្លះត្រូវបានទទួលរងនូវផលប៉ះពាល់ពីគ្រោះទឹកជំនន់ និងគ្រោះខ្វះទឹក ដែលបានបង្កឱ្យខូចខាតចំនួន ៤៩.០៥១ហិកតា ក៏ដោយ។ ទោះបីជាយ៉ាងណា ការបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤មកទល់ពេលនេះត្រូវបានបញ្ចប់ជាស្ថាពរហើយដោយអនុវត្តបានចំនួន២.៥៦៤.៤២៨ហិកតា ស្មើនឹង១០៦,៣៥% នៃផែនការ២.៤១១.២០៧ហ.ត គឺលើសពីឆ្នាំមុន១.៦៦៤ហ.ត។ បច្ចុប្បន្នប្រជាកសិករក្នុងខេត្តមួយចំនួនក៏បានចាប់ផ្តើមប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៤យ៉ាងមមាញឹក ដោយគិតមកទល់ពេលនេះគឺសម្រេចបានចំនួន៦៣៣.៤៦៣ហិកតា ស្មើនឹង២៤.៧០%នៃផ្ទៃដីអនុវត្ត ។

ជារួម លទ្ធផលដែលទទួលបានប្រកបដោយមោទនភាពនេះ គឺស្តែងចេញពីការដឹកនាំប្រកបដោយគតិបណ្ឌិតឈ្លាសវៃបំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចសហប្រតិបត្តិការល្អពីក្រសួង ស្ថាប័នពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធ ដៃគូអភិវឌ្ឍ ផលិតករ ប្រជាកសិករ ព្រមទាំងអំណោយផលល្អបង្គួរពីធម្មជាតិផងដែរ។

តាមការសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI-អ៊ីរី) បានបង្ហាញថា បរិមាណនៃការបាត់បង់ស្រូវក្រោយពេលប្រមូលផលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍គឺមានប្រមាណពី១០% ទៅ២៥% និងពី ២០% ទៅ៣០% នៃតម្លៃសរុប។ ក្នុងគោលបំណងដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវការបាត់បង់ស្រូវ អង្ករ ទាំងបរិមាណ និងគុណភាព នៅក្នុងនិងក្រោយពេលប្រមូលផលដែលធ្វើឱ្យប្រជាកសិករខាតបង់ផលចំណេញ ពិបាកប្រកួតប្រជែងខាងគុណភាព និងពុំមាននិរន្តរភាពនៅលើទីផ្សារជាតិនិងអន្តរជាតិនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្តទូទាំងប្រទេស ត្រូវយកចិត្តទុកដាក់ខ្ពស់ ដើម្បីណែនាំដល់ប្រជាកសិករ ផលិតករ និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យអនុវត្តនូវវិធានការចាំបាច់មួយចំនួន ដូចខាងក្រោម៖

១. នៅពេលស្រូវមិនទាន់ទុំល្អ ត្រូវរក្សាឱ្យមានទឹកគ្រប់គ្រាន់នៅក្នុងស្រែជានិច្ច។ ការបង្ហូរទឹកចេញពីស្រែគួរធ្វើនៅពេលដែលគ្រាប់ស្រូវនៅចុងកួរភាគច្រើនជាក់មៀរឹងនិងប្រែពណ៌ទៅជាលឿង ឬប្រមាណជា១សប្តាហ៍មុនពេលច្រូតកាត់ ពីព្រោះថាបើខ្វះទឹក ស្រូវនឹងជាក់គ្រាប់មិនបានពេញល្អ ធ្វើឱ្យស្ត.../

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

និងពោះអង្ករឡើងព៌ណ៌ ស ច្រើន។ ផ្ទុយទៅវិញ ការបង្ហូរទឹកចេញពីស្រែយឺតពេក ក៏នឹងធ្វើឱ្យមានការលំបាកក្នុងការច្រូតកាត់ និងដឹកជញ្ជូន ហើយក្នុងករណីដើមស្រូវដួលក៏នឹងធ្វើឱ្យខូចគុណភាពគ្រាប់អង្ករផងដែរ។

២. ត្រូវច្រូតស្រូវនៅពេលដែលស្រូវទុំល្អ គឺនៅក្រោយពេលស្រូវចេញផ្កាពេញលេញប្រមាណជា៣០ថ្ងៃ ទៅ៣៥ថ្ងៃ ពោលគឺនៅពេលដែលគ្រាប់មានអត្រាសំណើមពី២០% ទៅ២៥% ហើយមានសភាពរឹង តែមិនស្រួយនៅពេលខាំ ឬ មានកម្រិតទុំក្នុងកួរ ឬ ទុំក្នុងស្រែពី៨០% ទៅ៨៥%។ ការច្រូតកាត់យឺតនឹងធ្វើឱ្យគ្រាប់ស្រូវស្ងួតជ្រុល ឬ ទុំញោស បណ្តាលឱ្យជ្រុះខ្ចាត់ខ្ចាយច្រើន ព្រមទាំងធ្វើឱ្យងាយប្រេះស្រាំនៅពេលបោកបែន ហើយបាក់គ្រាប់អង្ករច្រើននៅពេលកិន។ តែបើឆាប់ច្រូតពេក គ្រាប់ស្រូវជាច្រើននឹងនៅស្ទើរ ធ្វើឱ្យពិបាកបោកបែន គ្រាប់មានភាពស្គើង មានសាច់ខាងក្នុងផុសៗ ដូចដីស ធ្វើឱ្យទទួលបានកន្ទក់ និងអង្ករបាក់ច្រើននៅពេលកិន ហើយអង្ករមានសម្បុរមិនសូវល្អ។

៣. បើច្រូតកាត់ដោយប្រើម៉ាស៊ីនច្រូតស្វ័យប្រវត្តិ (កុំបែច្រូត) អ្នកបញ្ជាម៉ាស៊ីនត្រូវច្រូតកាត់ដោយប្រុងប្រយ័ត្ន ប្រើប្រាស់ល្បឿនច្រូតយឺតប្រមាណជា៥គីឡូម៉ែត្រ/ម៉ោង ហើយត្រូវពិនិត្យនិងផ្លាស់ប្តូរគ្រឿងបន្លាស់ចាស់ៗឬដែលខូចចេញ ដើម្បីកាត់បន្ថយការបាត់បង់ និងទទួលបានគ្រាប់ស្រូវស្អាតល្អ។

៤. ត្រូវដាក់កណ្តាប់ស្រូវដែលច្រូតកាត់រួចនៅកន្លែងស្ងួតឱ្យផុតពីទឹក ឬ ដីសើម ដើម្បីចៀសវាងការធ្វើឱ្យទទឹកគ្រាប់ស្រូវ ហើយត្រូវប្រញាប់ធ្វើការបោកបែននិងហាលសម្ងួត។ ការទុកកណ្តាប់ចោលយូរនៅក្នុងស្រែអាចនឹងធ្វើឱ្យគ្រាប់ស្រូវងាយខូចដោយទឹកភ្លៀង ទឹកសន្សើមក៏ដូចជាការបំផ្លាញរបស់សត្វស្លាប សត្វកណ្តុរ និងសត្វចង្រៃផ្សេងៗទៀត។

៥. ការប្រមូលនិងដឹកជញ្ជូនកណ្តាប់ស្រូវទៅកាន់ទីលានបោកបែនត្រូវធ្វើដោយប្រុងប្រយ័ត្ន ដើម្បីចៀសវាងការជ្រុះខ្ចាត់ខ្ចាយគ្រាប់ស្រូវ។ ម្យ៉ាងទៀត ដើម្បីរក្សាភាពសុទ្ធនៃពូជ ត្រូវចៀសវាងកុំប្រមូលដឹកនិងបោកបែនកណ្តាប់ស្រូវដែលមានពូជលាយចម្រុះជាមួយគ្នា។

៦. ត្រូវបោកបែនស្រូវដោយប្រុងប្រយ័ត្ន ចៀសវាងកុំធ្វើឱ្យគ្រាប់ស្រូវបែក ប្រេះស្រាំ និងរលាត់ ដែលធ្វើឱ្យងាយទទួលរងផលប៉ះពាល់មិនល្អពីអាកាសធាតុ ការបំផ្លាញពីជំងឺ និងសត្វចង្រៃនានា និងជាពិសេសធ្វើឱ្យអង្ករបាក់ច្រើននៅពេលកិន។

៧. នៅពេលបោកបែនដោយម៉ាស៊ីន ត្រូវសម្រួលឱ្យត្បាល់ម៉ាស៊ីនវិលក្នុងល្បឿនសមស្របគឺ៦០០ជុំ/នាទី ឬ ចុងធ្មេញត្បាល់រត់ក្នុងល្បឿន ១២ ម៉ែត្រ/វិនាទី។ ក្នុងករណីដែលល្បឿននេះទាបពេក គឺធ្វើឱ្យម៉ាស៊ីនបោកយឺតឬប្រឡេះគ្រាប់ស្រូវចេញពីចំបើងមិនអស់។ ផ្ទុយទៅវិញ បើល្បឿននេះលឿនពេក គឺធ្វើឱ្យគ្រាប់ស្រូវរងនូវកម្លាំងវាយផ្ទប់ខ្លាំងដែលធ្វើឱ្យងាយបែក ឬ រលាត់សម្បក និងប្រេះស្រាំគ្រាប់អង្ករ។

៨. ទោះច្រូតកាត់និងបោកបែនដោយវិធីណាក៏ដោយ ក៏ត្រូវហាលសម្ងួតគ្រាប់ស្រូវឱ្យបានឆាប់តាមតែអាចធ្វើទៅបាន ព្រោះការរក្សាទុក ឬផ្អាប់គ្រាប់ស្រូវសើមលើសពី២៤ម៉ោង ធ្វើឱ្យគុណភាពស្រូវ អង្ករចាប់ផ្តើមថយចុះ។

៩. ត្រូវហាលសម្ងួតស្រូវក្នុងកម្រាស់ពី ២ស.ម ទៅ ៤ស.ម ហើយឧស្សាហ៍ត្រឡប់ ពិសេសនៅពេលថ្ងៃក្តៅខ្លាំង ពីព្រោះសីតុណ្ហភាពឡើងខ្ពស់ជាង ៤២ អង្សាសេ នឹងធ្វើឱ្យអង្ករបាក់ច្រើនពេលកិន ហើយធ្វើឱ្យស្រូវពូជលែងដុះប្រសិនបើត្រូវទុកជាគ្រាប់ពូជស្រូវសម្រាប់ដាំដុះបន្ត។

១០. ចំពោះការសម្ងួតគ្រាប់ស្រូវដោយម៉ាស៊ីនសម្ងួត សីតុណ្ហភាពសម្ងួតមិនត្រូវឱ្យលើសពី ៤២ អង្សាសេឡើយ។ អត្រាសំណើមស្រូវសម្រាប់ទុកបរិភោគគឺ១៤% ហើយសម្រាប់ធ្វើជាគ្រាប់ពូជគឺ១២%។

១១. ត្រូវសម្អាតគ្រាប់ស្រូវឱ្យបានស្អាតត្រឹមត្រូវល្អ ដោយរែង អុំ រោយ ឬ បក់យកចេញឱ្យអស់នូវគ្រាប់ស្មៅ ឬ កម្ទេចកម្ទីសំរាមផ្សេងៗ ពីព្រោះភាពមិនស្អាតអាចធ្វើឱ្យស្រូវឡើងកម្តៅ ជាជម្រករបស់សត្វល្អិត និងកត្តាចង្រៃនានា ដែលនឹងបណ្តាលឱ្យគ្រាប់ស្រូវងាយអន់គុណភាព។ ចាំបាច់ត្រូវប្រើប្រាស់សម្បកបាវស្ងួតនិងស្អាត ហើយសម្អាតកន្លែងទុកដាក់ឱ្យបានស្អាតជាប្រចាំ។ បើអាចធ្វើបានគួរទុកដាក់ស្រូវដែលបានហាលស្ងួតត្រឹមត្រូវនៅក្នុងសម្ភារ ឬឧបករណ៍ដែលបិទជិត។

១២. ត្រូវរៀបចំជង្រុក ឬ កន្លែងទុកដាក់គ្រាប់ស្រូវឱ្យបានត្រឹមត្រូវនិងមានអនាម័យល្អ មានដំបូល និងជញ្ជាំងគត់មត់ដើម្បីរក្សាទុកគ្រាប់ស្រូវក្នុងស្ថានភាពមួយដែលអាចចៀសវាងបានពីការត្រូវទឹក និងឡើងកម្តៅ ព្រមទាំងការពារបានពីការបំផ្លាញដោយកត្តាចង្រៃផ្សេងៗ។

ទទួលបាននូវសេចក្តីណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវសហការឱ្យបានល្អជាមួយអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ ពាណិជ្ជករ ផលិតករ ម្ចាស់ម៉ាស៊ីនកិនស្រូវ ព្រមទាំងកសិករមានវិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ការបាត់បង់ទាំងបរិមាណ និងគុណភាពស្រូវរដូវវស្សាឆ្នាំ២០១៤ ទាំងនៅកំឡុងពេលនិងនៅក្រោយពេលប្រមូលផល សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ឱ្យទទួលបានជោគជ័យ ក្នុងន័យធានាបាននូវសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ បង្កើនសន្ទុះការនាំចេញអង្ករ និងការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ។ ៧/៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងព័ត៌មាន
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- អាជ្ញាធរជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត

*"ដើម្បីជូនជ្រាប"*

- អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្មរាជធានី ខេត្ត

*"ដើម្បីអនុវត្ត"*

- ឯកសារ កាលប្បវត្តិ